ក្រសួងអប់រំ យុវជន និងកីឡា

# ការយល់ដឹងអំពីការកែទម្រង់ដំណើរការបង្រៀន និងរៀន នៅកម្ពុជា

រៀបចំដោយ៖ អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា

ថ្ងៃទី ០៩ ខែសីហា ឆ្នាំ២០២១

# មាតិកា




1. បញ្ហាសំខាន់ៗទាក់ទងនឹងការវិវត្តគរុកោសល្យនៅកម្ពុជា
2. ការយល់ដឹងពីការអប់រំនៅសតវត្សរ៍ទី ២១
3. របៀបនៃការគិតអំពី គោលវិធីអប់រំ វិធីសាស្ត្រអប់រំ និងល្បិចអប់រំ
4. ការប្រើវិធីសាស្ត្របែបសំយោគ (Hybridized Teaching) ក្នុងការបង្រៀន និងការរៀន
5. សេចក្តីសន្និដ្ឋានសំខាន់ៗមួយចំនួនដើម្បីស្វែងយល់

# ១. បញ្ហាសំខាន់ៗទាក់ទងនឹងការវិវត្តគរុកោសល្យនៅកម្ពុជា

- ការវិវត្តជាប្រវត្តិសាស្ត្រនៃគរុកោសល្យនៅកម្ពុជាត្រូវបានកំណត់លក្ខណៈថាជាការស្វែងរកគោលលទ្ធិត្រឹមត្រូវ (orthodoxy) និងការស្វែងយល់អំពីរូបមន្តគរុកោសល្យ...
- ការស្វែងរកគោលលទ្ធិត្រឹមត្រូវ បានជួបផលវិបាកមិនល្អមួយចំនួន៖
  - អ្នកអប់រំចំណាយពេលវេលាដ៏ច្រើនដើម្បីជជែកវែកញែកអំពីនិយមន័យ និងការធ្វើចំណាត់ថ្នាក់នៃបញ្ញត្តិ យោងទៅតាមរូបមន្តតឹងរ៉ឹង ដែលមានទំនាក់ទំនងតិចតួច ទៅនឹងបញ្ហាដែលគ្រូក្នុងថ្នាក់កំពុងប្រឈម...
  - ការអនុវត្តការអប់រំមានលក្ខណៈធ្វើតាមរូបមន្ត និងរ៉ាយរ៉ាប់កម្រិតខ្ពស់
  - គ្រូគិតតែអំពី តើបច្ចេកទេស "អ្វីខ្លះ" ដែលពួកគេគួរប្រើក្នុងការបង្រៀនជាជាង "ហេតុអ្វី" ពួកគេកំពុងប្រើវា

# ការបង្រៀនបែបរ៉ាយរ៉ាប់ និងធ្លុះបញ្ចាំង

- ការអនុវត្តការអប់រំនៅប្រទេសកម្ពុជាត្រូវបានកំណត់ជាយូរមកហើយ ថាមានភាពតានតឹងរវាងការបង្រៀនរ៉ាយរ៉ាប់ និងការបង្រៀនបែបធ្លុះបញ្ចាំង
  - ការបង្រៀនបែបរ៉ាយរ៉ាប់ លើកកម្ពស់វិធីរៀន ទៅតាមជំហាននៃការបង្រៀន ដែលមានការរៀបចំស្រាប់សម្រាប់គ្រូ និងដែលមានវិសាលភាពគម្លាតតិចតួច។
  - ការបង្រៀនធ្លុះបញ្ចាំង លើកកម្ពស់វិធីរៀនមួយ ដែលគ្រូមានសេរីភាពច្រើន ក្នុងការផ្សំបច្ចេកទេសពីវិធីសាស្រ្តបង្រៀនជាច្រើនឱ្យសមស្របនឹងបរិបទនៃថ្នាក់រៀនរបស់គាត់។
- ជាការពិតណាស់ វិធីសាស្ត្រនីមួយៗ ពិតជាមានគុណសម្បត្តិ និងគុណវិបត្តិផ្ទាល់ខ្លួន។ ជម្រើសនៃវិធីសាស្រ្តអាស្រ័យលើរបៀបដែលប្រព័ន្ធអប់រំកំណត់អាទិភាពរបស់វា។

# គុណសម្បត្តិ និងគុណវិបត្តិ នៃការបង្រៀនបែបរ៉ាយរ៉ាប់ និងឆ្លុះបញ្ចាំង

| | គុណសម្បត្តិ | គុណវិបត្តិ |
|---|---|---|
| **ការបង្រៀនបែបរ៉ាយរ៉ាប់** | • លួសម្រាប់បង្រៀនមូលដ្ឋានគ្រឹះ<br>• សមស្របសម្រាប់គ្រូដែលមានកម្រិតបណ្ដុះបណ្ដាលទាប<br>• គ្រូបង្រៀនមិនចាំបាច់គិតច្រើនពីការបង្រៀនរបស់ពួកគេទេ<br>• ងាយស្រួលសម្រាប់ការងារអធិការកិច្ចតាមដានអនុលោមភាព។ | • មិនមានប្រយោជន៍សម្រាប់ការបង្រៀនបំណិនគិតកម្រិតខ្ពស់ទេ<br>• មិនសមស្របសម្រាប់គ្រូដែលមានសមត្ថភាពខ្ពស់<br>• គ្រូបង្រៀនមានសេរីភាពតិចតួចក្នុងការសម្របការបង្រៀនរបស់ពួកគេទៅនឹងបរិបទជាក់លាក់<br>• គ្រូបង្រៀនមានវិសាលភាពតិចតួចសម្រាប់ការរីកចម្រើនវិជ្ជាជីវៈ |
| **ការបង្រៀនបែបឆ្លុះបញ្ចាំង** | • ល្អសម្រាប់បង្រៀន ទាំងបំណិនគិតកម្រិតទាប និងខ្ពស់<br>• សមស្របសម្រាប់គ្រូដែលមានសមត្ថភាពខ្ពស់<br>• ផ្ដល់នូវវិសាលភាពបន្ថែមទៀត សម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈរបស់គ្រូ | • គ្រូដែលមានកម្រិតសមត្ថភាពទាបមានការលំបាកច្រើន<br>• មានការលំបាកច្រើនក្នុងការអនុវត្ត និងតាមដាន<br>• ការឆ្លុះបញ្ចាំងត្រូវការពេលវេលាដើម្បីអនុវត្ត |

# ជម្រើសរបស់ប្រទេសកម្ពុជា...




- អ្នកអប់រំខ្លះបានអះអាងថាវិធីសាស្ត្របែបរ៉ាយរ៉ាប់មានសារប្រយោជន៍សម្រាប់ប្រទេសកម្ពុជាកាលពី ២០ ឆ្នាំមុននៅពេលដែលគ្រូភាគច្រើនមិនមានសមត្ថភាព
- ទោះយ៉ាងណាក៏ដោយ...ឥឡូវនេះដល់ពេលដែលប្រទេសកម្ពុជាត្រូវឈានទៅមុខ ហើយចាប់ផ្តើមផ្លាស់ប្តូរពីវិធីសាស្ត្របែបរ៉ាយរ៉ាប់ទៅជាការបង្រៀនបែបឆ្លុះបញ្ចាំង
- នេះគឺជាមធ្យោបាយតែមួយគត់ដែលគ្រូនឹងកាន់តែមានជំនាញវិជ្ជាជីវៈ។

# ២. ការយល់ដឹងពីការអប់រំនៅសតវត្សរ៍ទី ២១




- ចលនាឆ្ពោះទៅរកវិធីសាស្ត្របង្រៀនថ្មីៗ ដូចជា IBL និង PBL ត្រូវបានជំរុញយ៉ាងខ្លាំងដោយការផ្លាស់ប្តូរសេដ្ឋកិច្ចក្នុងសតវត្សរ៍ទី ២១
- បទបង្ហាញដែលបានគ្រោងទុក ព្យាយាមបង្ហាញពីទំនាក់ទំនងរវាងសេដ្ឋកិច្ចនៅសតវត្សរ៍ទី ២១ និងការផ្លាស់ប្តូរលើការអប់រំ។
- ការយល់ដឹងអំពីការផ្លាស់ប្តូរទាំងនេះ នឹងជួយអ្នកអប់រំឱ្យយល់ពីមូលហេតុដ៏សំខាន់នៃការអនុម័តវិធីសាស្ត្របង្រៀនថ្មីៗ និងការរៀបចំសាលារៀនឡើងវិញ
- បទបង្ហាញនេះផ្តល់នូវមូលដ្ឋានល្អសម្រាប់ការពិភាក្សានៅពេលក្រោយ។

# ហេតុផលសំខាន់មួយទៀតដែលយើងត្រូវការវិធីសាស្រ្តបង្រៀនថ្មី គឺទាក់ទងនឹងតម្រូវការនៃការសិក្សាសតវត្សរ៍ទី ២១ ...




- ផ្នែកនេះសង្ខេបពីភាពផ្ទុយគ្នារវាងការអប់រំនៅសតវត្សរ៍ទី ២០ និងទី ២១ និងរបៀបដែលយើងត្រូវការផ្លាស់ប្តូរសម្រាប់សតវត្សរ៍ថ្មី
- នេះសំដៅទៅលើការផ្លាស់ប្តូរពីស្ថានភាពដែលមានភាពនឹងថ្កល់ ទៅជារបៀបមួយដែលមានភាពឌីណាមិក និងតម្រូវការប្រព័ន្ធអប់រំមួយដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរនេះ ជាពិសេសទាក់ទងនឹងគរុកោសល្យបង្រៀន។

# កន្លែងធ្វើការរបៀបចាស់ និងបន្ទប់រៀនរបៀបចាស់ - ដែលមានសភាពដូចគ្នា



កន្លែងធ្វើការសតវត្សរ៍ទី ២០




ថ្នាក់រៀនសតវត្សរ៍ទី ២០

# តើសង្គមប្រែប្រួលយ៉ាងដូចម្តេច?

- ចំណេះដឹងលែងមានស្ថិរភាពដូចនៅសតវត្សរ៍ទី ២០ទៀតឡើយ
  - ការបង្រៀនដែលប្រើតែសៀវភៅសិក្សាគោលគឺហួសសម័យ
- ម៉ាស៊ីនកំពុងធ្វើការជំនួសមនុស្ស
- ការងារកំពុងបាត់បង់
- ការងារថ្មីកំពុងកើតឡើង
- យើងត្រូវការបណ្តុះបណ្តាលមនុស្សឱ្យធ្វើអ្វីដែលម៉ាស៊ីនមិនអាចធ្វើបាន

# ការផ្លាស់ប្តូរពីការសិក្សាបែបសតវត្សទី ២០ ទៅសតវត្សទី ២១...

| កត្តាវាស់វែង | ការអប់រំបែបសតវត្សទី២០ | ការអប់រំបែបសតវត្សទី២១ |
|---|---|---|
| • បញ្ញត្តិនៃការរៀន | • ការផ្ទេរព័ត៌មាន<br>• ការរៀនបែបអកម្ម<br>• ការរៀនបែបទន្ទេញ | • សិស្សរៀនដោយខ្លួនឯង<br>• ការរៀនបែបសកម្ម<br>• ការរៀនបែបបញ្ញត្តិ |
| • កម្មវិធីសិក្សា | • រៀបជាស្តង់ដា<br>• ប្រើតែសៀវភៅសិក្សាគោល | • លក្ខណៈបុគ្គល<br>• រៀបចំបែបបញ្ញត្តិ<br>• បែបស្រាវជ្រាវ<br>• មិនប្រើតែសៀវភៅសិក្សាគោលមួយមុខនោះទេ |
| • ការវាយតម្លៃ | • ធ្វើតែតេស្តវាយតម្លៃ | • ផ្តោតលើការបង្កើតកម្រងស្នាដៃ |
| • របៀបរៀបចំថ្នាក់រៀន | • រៀបជាស្តង់ដា<br>• របៀបរៀបចំគ្រឿងសង្ហារិមមិនប្រែប្រួល (ឧ. ជួរត្រង់) | • របៀបរៀបចំគ្រឿងសង្ហារិមប្រែប្រួល ឬ បត់បែន<br>• របៀបរៀបចំដែលបម្រើដល់ការងារក្រុម |
| • របៀបរៀបចំសាលារៀន | • ឋានានុក្រម | • របៀបរៀបចំដែលជំរុញការបង្កើតជាបណ្តាញ និងការទំនាក់ទំនង |
| • ទស្សនវិជ្ជាអប់រំ | • អនុលោមភាព<br>• ភាពដូចគ្នា<br>• ឯកសណ្ឋានភាព | • ការរៀនបែបឌីណាមិក<br>• ការរៀនតាមរបៀបប្លែកៗគ្នា<br>• ការរៀនដែលជំរុញការបង្កើតថ្មី |
| • ស្ថាបត្យកម្មសាលារៀន | • ឯកសណ្ឋានភាព<br>• រៀបជាស្តង់ដា | • បែបឌីណាមិក<br>• មិនមានស្តង់ដា |

# ៣. របៀបនៃការគិតអំពី គោលវិធីអប់រំ វិធីសាស្ត្រអប់រំ និងល្បិច អប់រំ




- អស់រយៈពេលជាច្រើនឆ្នាំមកហើយ អ្នកអប់រំនៅកម្ពុជាក៏បានព្យាយាមធ្វើឱ្យមានលក្ខណៈជាប្រព័ន្ធ និងធ្វើឱ្យមានលក្ខណៈស្តង់ដាលើវិធីប្រើពាក្យ និងបញ្ញត្តិខុសៗគ្នា។
- ការពិភាក្សាពីភាពខុសគ្នារវាងគោលវិធី វិធីសាស្ត្រ និងល្បិច ត្រូវបានធ្វើឡើង។
- ជាថ្មីម្តងទៀត ការពិភាក្សាបែបនេះ គឺជាដំណើរស្វែងរកមួយទៀតនូវគោលលទ្ធិត្រឹមត្រូវ (orthodoxy) ដែលជាគ្រោះថ្នាក់ដូចដែលយើងបានពិភាក្សារួចហើយ។
- គ្រោះថ្នាក់នោះគឺថាការពិភាក្សាបែបនេះ ត្រូវការពេលវេលាច្រើន ហើយជារឿយៗមានភាពពាក់ព័ន្ធតិចតួច ចំពោះបញ្ហាជាក់ស្តែងដែលគ្រូប្រឈមមុខនៅក្នុងថ្នាក់រៀនរបស់ពួកគេ...

# ទោះយ៉ាងណាក៏ដោយ... វាជាការពិតណាស់ដែលយើងត្រូវឱ្យនិយមន័យពាក្យរួមមួយ ដែលអាចមានប្រយោជន៍...

- ឧទាហរណ៍, ...
- ជាលក្ខណៈអន្តរជាតិ គោលវិធីត្រូវបានគេមើលឃើញជាទូទៅថាមានឋានានុក្រមស្ថិតនៅកំពូលគេនៃប្រព័ន្ធអប់រំ ខណៈដែល វិធីសាស្ត្រ និង ល្បិចស្ថិតនៅខាងក្រោមជាបន្តបន្ទាប់ ...



# នេះគឺជាវិធីដែលយើងអាចកំណត់ជាប្រព័ន្ធឋានានុក្រមដើម្បីរៀបចំឱ្យបានល្អប្រសើរនូវពាក្យដែលបានប្រើញឹកញាប់...

- នៅក្នុងក្របខណ្ឌដែលបានបង្ហាញនៅខាងស្តាំ យើងកំណត់ គោលវិធី ថាជាទស្សនវិជ្ជានៃការបង្រៀននិងរៀន ( ឧ. ស្ថាបនានិយម វឌ្ឍនភាពនិយម។ ល។ )
  - គោលវិធីបែបទស្សនវិជ្ជា មានគោលការណ៍ជាលក្ខណៈអរូបី ដែលផ្តល់ជាមគ្គុទ្ទេសន៍សម្រាប់ការអភិវឌ្ឍវិធីសាស្ត្របង្រៀន...
- នៅក្នុងគោលវិធី មានវិធីសាស្ត្រច្រើនបែប ( ឧ. IBL, PBL ។ ល។ )
- ហើយនៅក្នុងវិធីសាស្ត្រមួយ អាចមានល្បិចច្រើនបែបផងដែរ...

| | |
|---|---|
| **គោលវិធីបង្រៀន** (Educational Approach) | •ស្ថាបនានិយម (Constructivism)<br>•វឌ្ឍនភាពនិយម (Progressivism)<br>•មូលដ្ឋាននិយម (Essentialism) |
| **វិធីសាស្ត្របង្រៀន** (Educational Methodology) | •ការសិក្សាបែបរិះរក (Inquiry based Learning)<br>•ការសិក្សាបែបសហការ (Cooperative Learning) |
| **ល្បិចបង្រៀន** (Educational Techniques) | •សិស្សរៀនជាក្រុម<br>•សិស្សស្រាវជ្រាវ<br>•សិស្សធ្វើបទបង្ហាញ |

| គោលវិធី (ឬ ទស្សនវិជ្ជា) | គំរូវិធីសាស្ត្រ | លក្ខណៈទាក់ទងនឹងវិធីសាស្ត្រ |
|---|---|---|
| ស្ថាបនានិយម៖<br><br>ស្ថាបនានិយម គឺជា "គោលវិធីសិក្សាដែលធ្វើឱ្យសិស្សស្ថាបនា ឬបង្កើតចំណេះដឹងផ្ទាល់ខ្លួន ហើយចំណេះដឹងពិត ត្រូវបានកំណត់ផ្អែកលើបទពិសោធន៍របស់សិស្ស" | វិធីសាស្ត្របែបគម្រោង (Project Method) | • ការកំណត់គម្រោង<br>• សិស្សធ្វើការជាក្រុម<br>• សិស្សស្រាវជ្រាវ<br>• សិស្សធ្វើបទបង្ហាញ |
| | វិធីសាស្ត្រសិក្សាបែបរិះរក (Inquiry-based Learning Method) | • សិស្សកំណត់សំណួរដែលពួកគេចង់រកចម្លើយ<br>• សិស្សស្រាវជ្រាវ<br>• សិស្សធ្វើបទបង្ហាញ<br>• សិស្សធ្វើការឆ្លុះបញ្ចាំង លើដំណើរការដែលល្អនិងមិនល្អ |
| | វិធីសាស្ត្រសិក្សាអាស្រ័យលើបញ្ហា (Problem-based Learning Method) | • ជំហានទី ១៖ ស្វែងយល់ និងកំណត់បញ្ហា<br>• ជំហានទី ២៖ សិស្សនិយាយពីអ្វីដែលពួកគេបានដឹង...<br>• ជំហានទី ៣៖ សិស្សកំណត់និយមន័យបញ្ហា ...<br>• ជំហានទី ៤៖ សិស្សស្រាវជ្រាវចំណេះដឹង ...<br>• ជំហានទី ៥៖ ស៊ើបអង្កេតរកដំណោះស្រាយ ...<br>• ជំហានទី ៦៖ បង្ហាញ និងគាំទ្រដំណោះស្រាយដែលបានរកឃើញ ...<br>• ជំហានទី ៧៖ សិស្សត្រួតពិនិត្យលទ្ធផលការងារពួកគេឡើងវិញ។ |

នេះគឺជាឧទាហរណ៍នៃការប្រើក្របខណ្ឌការសិក្សាបែបស្ថាបនានិយម...

# ប៉ុន្តែយើងគួរចងចាំថា ការចាត់ជាប្រភេទទាំងអស់នេះ មិនមែនយើងអាចកាត់ផ្ដាច់ចេញពីគ្នាទាំងស្រុង ដូចដែលយើងចង់បាននោះទេ...

- ដោយហេតុនេះហើយ ទើបពាក្យ **យុទ្ធសាស្ត្រ** ( Strategies) ត្រូវបានយកមកប្រើ...
- គ្រូម្នាក់កម្រប្រើគោលវិធីមួយ ឬ វិធីសាស្ត្រតែមួយគ្រប់ពេលនោះទេ។
- ជារឿយៗ គ្រូត្រូវបានគេរំពឹងថានឹងបញ្ចូលគ្នានូវធាតុផ្សំនៃគោលវិធី និងវិធីសាស្ត្រផ្សេងៗគ្នា អាស្រ័យលើបរិបទ។
- គ្រូតែងតែធ្វើសកម្មភាពជាក់លាក់ដើម្បីផ្សំ និងកែប្រែគោលវិធី វិធីសាស្ត្រ ដើម្បីដោះស្រាយបញ្ហាប្រឈមជាក់លាក់នៅក្នុងថ្នាក់រៀនរបស់ពួកគេ
- នៅពេលគ្រូចេះធ្វើបែបនេះ គឺពួកគេកំពុងបង្កើត**យុទ្ធសាស្ត្រ**។

# ករណីលើកលែង !



- សិក្ខាកាម គួរចងចាំថាក្របខណ្ឌដែលបានបង្ហាញខាងលើ គ្រាន់តែជាឧបករណ៍បញ្ញត្តិមួយ ដើម្បីគិតអំពីពាក្យ និងគំនិតផ្សេងៗគ្នា...
- វាមិនគួរត្រូវបានប្រើជាឧបករណ៍តឹងរ៉ឹង ដើម្បីស្វែងរកគោលលទ្ធិត្រឹមត្រូវបែបមនោគមន៍វិជ្ជា ( ideological orthodoxy ) ឡើយ...
- វាតែងតែមានករណីលើកលែង នៅពេលដែលក្របខណ្ឌនេះមិនអាចដំណើរការបាន...

# ៤. ការប្រើវិធីសាស្ត្របែបសំយោគ (Hybridized teaching) ក្នុងការបង្រៀននិងការរៀន

- ការអប់រំបែបថ្មី ស្នើឱ្យប្រើវិធីសាស្ត្របែបសំយោគជាគរុកោសល្យដើម្បី លើកទឹកចិត្តឱ្យគ្រូចេះពិចារណាលើ " បរិបទអប់រំ" និង" គោលបំណង" ដែលត្រូវបង្រៀននៅពេលដែលកំណត់ពីរបៀបដែលពួកគេបង្រៀន។
- នៅពេលដែលគ្រូបង្រៀនពិចារណាលើគោលបំណងអប់រំរបស់ពួកគេនិង កំណត់បរិបទអប់រំដោយយកចិត្តទុកដាក់ មានន័យថាគ្រូបង្រៀនចេះ សំយោគល្បិចពីវិធីសាស្ត្រផ្សេងៗគ្នាជាច្រើន។
- ការចេះប្រើល្បិចភាគច្រើនទាំងនេះមកបញ្ចូលគ្នា (សំយោគ ឬកូនកាត់) គេហៅថាការរៀនតាមគោលវិធី ស្ថាបនានិយម ដែលជួយបន្ថយការប្រកួតប្រជែងរវាងវិធីសាស្ត្របង្រៀនផ្សេងៗ...

# ការយល់ដឹងអំពីគោលវិធីសិក្សាបែបស្ថាបនានិយម




- គោលវិធីបង្រៀនថ្មី ផ្តោតលើការជួយអ្នកអប់រំឱ្យយល់ពីអ្វីដែលហៅថា ការសិក្សាបែបស្ថាបនានិយម និងបង្ហាញពីមូលហេតុដ៏សំខាន់របស់វា
- ការសិក្សាបែបស្ថាបនា មិនមែនជាវិធីសាស្រ្តបង្រៀនទេ ប៉ុន្តែជាទ្រឹស្តីនៃការបង្រៀននិងរៀនឬជាគោលវិធី ដែលបញ្ចូលគ្នានូវវិធីសាស្រ្តបង្រៀនជាច្រើនដែលកំពុងពេញនិយមនាពេលបច្ចុប្បន្ននេះ...
- ការសិក្សាបែបស្ថាបនានិយម គឺជាទ្រឹស្តីអប់រំសមស្របសម្រាប់សតវត្សរ៍ទី ២១ ដោយសារតែវាផ្តោតទៅលើការលើកកម្ពស់ការគិតស៊ីជម្រៅ និងដោះស្រាយបញ្ហានៅក្នុងបរិបទណាមួយ...

# ការសិក្សាបែបស្ថាបនានិយម បញ្ចូលវិធីសាស្ត្របង្រៀន បែបរិះរក (IBL) អាស្រ័យលើបញ្ហា (PBL) បែបសហការ (CL) និងវិធីសាស្ត្របង្រៀនជាច្រើនទៀត...




ការសិក្សាបែបស្ថាបនានិយម

ការចាប់យកការសិក្សាបែបស្ថាបនានិយម មកអនុវត្ត ជួយដោះស្រាយនូវភាពប្រកួតប្រជែងគ្នារវាងវិធីសាស្ត្រទាំងអស់នេះ ពីព្រោះវិធីសាស្ត្រទាំងនេះ សុទ្ធតែខ្ចីគោលការណ៍ ពីការសិក្សាបែបស្ថាបនានិយម...

# ឧទាហរណ៍ពីរបៀបដំណើរការវិធីសាស្ត្របង្រៀនបែបសំយោគ (កូនកាត់)...

<table>
<tr><th>ឧទាហរណ៍អំពីបរិបទអប់រំ</th><th>ល្បិចពាក់ព័ន្ធនឹងវិធីសាស្ត្របង្រៀន</th><th>ការអនុវត្តវិធីសាស្ត្របង្រៀនបែបសំយោគ ឬ កូនកាត់ (យុទ្ធសាស្ត្រ)</th></tr>
<tr><td rowspan="3">ថ្នាក់រៀននៅតាមទីជនបទមួយមានសិស្សច្រើនដែលមានសិស្សជិត ៥០ នាក់។ សិស្សទាំងនេះមិនដែលធ្លាប់រៀនសូត្រដែលដឹកនាំដោយខ្លួនឯងពីមុនទេ ហើយជំនាញស្រាវជ្រាវក៏មានកម្រិត។ គោលបំណងនៃការសិក្សាមានដូចខាងក្រោម៖<br>• សិស្សអាចកំណត់បញ្ហាដែលទាក់ទងនឹងបរិស្ថាននៅក្នុងសហគមន៍របស់ពួកគេ។<br>• សិស្សអាចស្នើដំណោះស្រាយចំពោះបញ្ហាដែលពួកគេបានរកឃើញតាមរយៈការស្រាវជ្រាវនិងការពិភាក្សា។</td><td>ការសិក្សាបែបសហការ<br>• រៀបចំសិស្សជាក្រុមចម្រុះសមត្ថភាពពី៤ទៅ៦ក្រុម<br>• បែងចែកតួនាទីចូលរួមធ្វើការងារ<br>• គ្រូបង្រៀនដើរត្រួតពិនិត្យការងារក្រុម<br>• ក្រុមសិស្សធ្វើរបាយការណ៍ ឬបទបង្ហាញ</td><td rowspan="3">• គ្រូផ្តល់នូវបញ្ជីបញ្ហាដែលអាចកើតមានក្នុងបរិស្ថាន (ឧទាហរណ៍ការទុកដាក់សំរាម ការកែឆ្នៃ ការបំពុលខ្យល់ ការបំផុលទឹក) សម្រាប់សិស្សជ្រើសរើសនិងពិចារណាថាតើនេះជាបញ្ហាពិតនៅក្នុងបរិស្ថានរបស់ពួកគេដែរឬទេ។ បច្ចេកទេសនេះនៅតែផ្តល់ឱ្យសិស្សគ្រប់គ្រងលើបញ្ហាកំណត់បញ្ហា ប៉ុន្តែត្រូវទទួលស្គាល់ថាសិស្សមិនទាន់ស៊ាំនឹងការរៀនសូត្រដែលដឹកនាំដោយខ្លួនឯងនោះទេ។<br>• គ្រូបង្រៀនរៀបចំក្រុមចំនួន ៥ ក្រុមដែលមួយក្រុមៗមានសិស្សចំនួន ១០ នាក់ ប៉ុន្តែបង្កើនការពិនិត្យតាមដានជួយដើម្បីធានាថាសិស្សទាំងអស់បានចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចការនេះ។<br>• គ្រូប្រគល់កិច្ចការជាក់លាក់ឱ្យក្រុមនីមួយៗ (ឧ. បញ្ជាក់អ្វីដែលគេដឹងកំណត់បញ្ហា ប្រមូលឯកសារស្រាវជ្រាវ។ ល។)<br>• សិស្សម្នាក់ឬច្រើននាក់ជួយសរសេរលទ្ធផលរកឃើញនិងដំណោះស្រាយ។<br>• សិស្សម្នាក់ឬច្រើនឡើងបង្ហាញពីលទ្ធផលរកឃើញ / ដំណោះស្រាយ.</td></tr>
<tr><td>ការសិក្សាបែបរិះរក<br>• សិស្សកំណត់សំណួរដែលពួកគេចង់រកចម្លើយ<br>• សិស្សស្រាវជ្រាវ<br>• សិស្សធ្វើបទបង្ហាញ<br>• សិស្សឆ្លុះបញ្ចាំងលើដំណើរការដែលមានដំណើរការល្អ /មិនល្អ</td></tr>
<tr><td>ការសិក្សាអាស្រ័យលើបញ្ហា<br>• ជំហានទី ១៖ ស្វែងយល់ និងកំណត់បញ្ហា<br>• ជំហានទី ២៖ សិស្សនិយាយពីអ្វីដែលពួកគេបានដឹង...<br>• ជំហានទី ៣៖ សិស្សកំណត់និយមន័យបញ្ហា ...<br>• ជំហានទី ៤៖ សិស្សស្រាវជ្រាវចំណេះដឹង ...<br>• ជំហានទី ៥៖ ស៊ើបអង្កេតរកដំណោះស្រាយ ...<br>• ជំហានទី ៦៖ បង្ហាញ និងគាំទ្រដំណោះស្រាយដែលបានរកឃើញ ...<br>• ជំហានទី ៧៖ សិស្សត្រួតពិនិត្យលទ្ធផលការងារពួកគេឡើងវិញ។</td></tr>
</table>

# ៥. សេចក្តីសន្និដ្ឋានសំខាន់ៗមួយចំនួនដើម្បីស្វែងយល់...




- នៅពេលសិក្ខាសាលានេះបញ្ចប់ អ្នកសម្របសម្រួលសង្ឃឹមថាអ្នកចូលរួមនឹងអាចមើលឃើញនូវរូបភាពកាន់តែធំ នៃរបៀបគរុកោសល្យដែលបានវិវត្តនៅក្នុងព្រះរាជាណាចក្រ...
- នេះរួមបញ្ចូល ការយល់ដឹងបន្ថែមអំពីចំណុចដូចខាងក្រោម៖
  - ជៀសវាងការគិតតឹងរ៉ឹងពេក ចំពោះលំនាំអនុវត្តវិធីសាស្រ្តបង្រៀនផ្សេងៗដូចជា IBL និង PBL
  - បង្កើតទម្លាប់ក្នុងការសួរថា " ហេតុអ្វី" ព្រោះ យើងធ្វើអ្វីៗតាមមធ្យោបាយជាក់លាក់មួយ មិនមែនគ្រាន់តែសួរថា " អ្វី" ទៅ ដែលយើងត្រូវតែធ្វើនោះទេ" ...
  - បង្ហាញសារទៅកាន់អ្នកអប់រំដទៃទៀត អំពីរបៀបដែលការអប់រំនៅកម្ពុជាត្រូវតែផ្លាស់ប្តូរដើម្បីជួយឱ្យកម្ពុជាមានដំណើរការអប់រំល្អក្នុងសតវត្សរ៍ថ្មីនេះ។
  - អភិវឌ្ឍសមត្ថភាពក្នុងការបញ្ចូលវិធីសាស្រ្តផ្សេងៗគ្នា (វិធីសាស្រ្តបង្រៀនបែបសំយោគ) ជាច្រើន ដើម្បីបំពេញតាមបរិបទជាក់លាក់ ខណៈពេលដែលរក្សាបាននូវភាពត្រឹមត្រូវនៃគោលការណ៍ការសិក្សាបែបស្ថាបនានិយម។

# សូមអរគុណ